ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

ELECTRICITE DU CAMBODGE

លេខៈ ៣២៥៤ សជណ.ររក.មររជ

ថ្ងៃ ពុធ ០១ រោច ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមជម្រាបជូនសាធារណជនឲ្យបានជ្រាបថា ក្រោមការយកចិត្តទុកដាក់ខ្ពស់ក្នុងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទ **រាជរដ្ឋាភិបាលកម្ពុជា** បានដាក់ចេញនូវ "ផែនការយុទ្ធសាស្ត្របន្ថយអត្រាថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងផ្តល់ថវិកាប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីសម្រាប់ការបន្ថយអត្រាថ្លៃលក់នេះ"។ អនុវត្តន៍តាមផែនការនេះ នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទ នៃអគ្គិសនីកម្ពុជា (ហៅកាត់ថា "ម.អ.ជ.") ទទួលបន្ទុកទូទាត់ប៉ះប៉ូវថ្លៃលក់អគ្គិសនីសម្រាប់ការប្រើប្រាស់របស់គ្រួសារជនបទដែលប្រើប្រាស់អគ្គិសនីតាមផ្ទះ និងអ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទ ក្នុងវិស័យកសិកម្មពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ជូនអ្នកផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។

ដើម្បីឲ្យការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងពុំមានការរើសអើង ម.អ.ជ. សូមស្នើសេវាករដែលធ្វើសេវាកម្មអគ្គិសនីមេត្តាសហការដោយឈរលើស្មារតីទទួលខុសត្រូវខ្ពស់ និងផ្តល់ទិន្នន័យពីបរិមាណអគ្គិសនីដែលគ្រួសារជនបទបានប្រើប្រាស់តាមផ្ទះ និងអ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទក្នុងវិស័យកសិកម្មឲ្យបានសុក្រឹត និងត្រឹមត្រូវ រួមទាំងឯកសារពាក់ព័ន្ធជូនមក ម.អ.ជ. ដើម្បីពិនិត្យ និងទូទាត់ប៉ះប៉ូវថ្លៃលក់អគ្គិសនីបំពេញបន្ថែមជូនសេវាករ ក្រោមផែនការយុទ្ធសាស្ត្រនេះ ឲ្យទាន់ពេលវេលា។

ផែនការយុទ្ធសាស្ត្រនេះ ជាកម្មវិធីអនុវត្តចាប់ពីឆ្នាំ២០១៦ និងនៅបន្តអនុវត្តក្នុងឆ្នាំ២០២៤។

ដើម្បីឲ្យកម្មវិធីនេះអនុវត្តន៍ទៅមានប្រសិទ្ធភាពខ្ពស់ សូម លោក/លោកស្រី ដែលជាម្ចាស់អាជ្ញាបណ្ណត្រូវផ្តល់ចំណុចអាប់ស៊ីស (X) និងចំណុចអរដោនេ (Y) ទីតាំងភូមិសាស្ត្រ (WGS 1984) នៃអ្នកប្រើប្រាស់អគ្គិសនីប្រភេទកសិកម្ម ដើម្បីពិនិត្យ និងផ្តល់ជូន។ ព័ត៌មានលំអិតសូមចូល www.ref.gov.kh និងឈ្មោះ Channel Telegram "នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទ" និងព័ត៌មាន បន្ថែមសូមទំនាក់ទំនងមកលោក ជុំ ចាន់តារា ទូរស័ព្ទលេខ 011 244-246 ឬលោក កែវ សីហា ទូរស័ព្ទលេខ 015 776-770 ឬទាក់ទងមក ម.អ.ជ. តាមទូរស័ព្ទលេខ 023 997-600 ឬទូរសារលេខ 023 997-601 ឬអញ្ជើញមកទំនាក់ទំនងនៅនាយកដ្ឋាន ម.អ.ជ. មានទីតាំងនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**អគ្គនាយករងមូលនិធិអគ្គិសនីការូបនីយកម្មជនបទ**

ELECTRICITE DU CAMBODGE

**ជុន ពិសិដ្ឋ**

**ចម្លងជូនៈ**

- ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គនាយករងអគ្គិសនីកម្ពុជា
  ដើម្បី "គោរពជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

KINGDOM OF CAMBODIA

NATION RELIGION KING

ELECTRICITÉ DU CAMBODGE

Ref : 3254 EDC.REF

Phnom Penh, 24 April , 2024

# NOTICE

**Electricité du Cambodge (EDC)** honorably inform the public that under the highest consideration of improving the level of living standard of the population in rural area, the Royal Government of Cambodia (RGC) has issued "Strategic Planning for Reduction of Tariff for Sale of Electricity in the Kingdom of Cambodia by reimbursing the gap between actual cost and the tariff for sale of electricity". To implement this strategic planning, Department of Rural Electrification Fund of EDC (hereinafter referred to as the "REF") is in charge of reimbursing the gap between actual cost and the tariff for sale of electricity for use by the rural households and use for all types in agricultural sector from 9:00 p.m. to 7:00 a.m. as a subsidy to the licensees.

To implement this Strategic Planning in a transparent manner without discrimination, REF requests the electricity suppliers to cooperate and act in a highly responsible manner and provide data on the quantity of the energy used by the rural households and for all types in agricultural sector accurately and properly including the related documents, to REF for review and release of the subsidy payment under this Strategic Planning on time.

This Strategic Planning is on-going program from 2016 and will also be implemented in 2024.

In order to implement this program more effectively, Please Mr / Mrs, the electricity licensees submit a horizontal axis (X) and a vertical axis (Y) of the digital location (WGS 1984) of agricultural consumers to REF for reviewing their eligibilities and then offering as a package. For further information, please visit our website "**www.ref.gov.kh**" and Telegram Channel "នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទ" and / or Mr. Chum Chandara via 011 244-246 or Mr. Keo Seyha via 015 776-770 or REF via 023 997-600 or fax 023 997-601 or visit REF office located at building No. 205, National road No. 5, Sangkat Kilometer 6, Khan Russeykeo, Phnom Penh.

Sincerely yours,

**Mr. Chun Piseth**
Deputy Managing Director of EDC

Recipients:
-Royal Government of Cambodia Delegate in charge as Managing Director of EDC
-Electricity Authority of Cambodia for "information "
-Deputy Managing Directors of EDC
- File-Archive.